# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២២ លេខ០១ ត្រីមាសទី០១ ឆ្នាំ២០២២

# រាជកិច្ច

## ផ្សាយចេញពី

## ទីស្តីការគណៈរដ្ឋមន្ត្រី

### សារធាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម

២៩-១-២០២២ -ព្រះរាជក្រម នស/រកម/០១២២/០០២ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពី វិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ១

### ២~ព្រះរាជក្រឹត្យ

១-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០០១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ជាកិច្ចបច្ឆាមរណៈ ចំពោះ ឯកឧត្តម **គួ សាគីន** ដែលបានទទួលមរណភាព ៦

៣-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០០២ ស្តីពី និយ័តកម្ម តម្លើង ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ ដល់លោក **ឡាយ សំអឿន** នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ មកជាឋានន្តរស័ក្តិ វរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៧

៣-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០០៣ ស្តីពី និយ័តកម្ម តម្លើងក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ ដល់លោក **វណ្ណា ម៉ាច់** នៃក្របខ័ណ្ឌមន្ត្រីក្រមការ មកជាឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៨

៣-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០០៤ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **សូ មុនីរក្សា** ជានាយកសាលាជាតិរដ្ឋបាលមូលដ្ឋាន ស.ជ.រ.ម នៃក្រសួងមហាផ្ទៃ មានបុព្វសិទ្ធស្មើ អគ្គនាយក ៩

៣-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០០៥ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ដល់ វរសេនីយ៍ឯក **អ៊ុក ស្រីមុំ** នាយទាហាន ថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ១០

៣-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០០៦ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **ឯម ម៉ុនសាត** ជាជំនួយការអមក្រសួងបរិស្ថាន មានឋានៈស្មើ អគ្គនាយក ១១

៣-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០០៧ ស្តីពី ការតាំងស៊ប់ នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដល់មន្ត្រីរាជការ ៦ រូប ១២

៣-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០០៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ដល់សប្បុរសជន ២៦ រូប ១៤

៣-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០០៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **នាគ ស៊ីនសាន** (NIE XINSHAN) ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះ ជា **នាគ ស័គសាន** (NIE SHUOSHAN) ១៦

៣-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០១០ ស្តីពី ការផ្តល់គោរមងារឯកឧត្តម **ហេង ទ៉ាន់ដា** ជា ឧកញ៉ា ១៧

៣-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០១១ ស្តីពី ការផ្តល់គោរមងារឯកឧត្តម **តែ ឡូរិន** ជា ឧកញ៉ា ១៨

៣-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០១២ ស្តីពី ការផ្តល់គោរមងារឯកឧត្តម **ឌួង លាង** ជា ឧកញ៉ា ១៩

៣-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០១៣ ស្តីពី ការផ្តល់គោរមងារលោកជំទាវ **ទេព កុលាប** ជា ឧកញ៉ា ២០

៤-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០១៤ ស្តីពី ការតែងតាំងមុខតំណែងលោកជំទាវ **សុទ្ធ សុម៉ាលី** ជាអនុរដ្ឋលេខាធិការ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបន្ថែមលើមុខងារបច្ចុប្បន្ន ២១

៤-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០១៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ថាង យ៉ូលាំង (TANG, YULIANG)** ជនជាតិចិន សញ្ជាតិចិន ២២

៥-១-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០១២២/០១៦ ស្តីពី ការតែងតាំង និងផ្តល់ឋានៈគ្រូនគរបាលជាតិដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ១២ រូប ជាគ្រូនគរបាលជាតិ ឧត្តមកម្រិត១ ថ្នាក់លេខ២ មានឋានៈស្មើ អគ្គនាយក នៃក្រសួងមហាផ្ទៃ ២៣

## II~ក្រុមប្រឹក្សាធម្មនុញ្ញ

២៧-១-២០២២ -សេចក្តីសម្រេចលេខ ២១៦/០០១/២០២២ កបធ.ច ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ ២០២២ លើសំណុំរឿងលេខ ៤៦២/០០១/២០២២ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ២០២២ ២៤

## III~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

៣១-១២-២០២១ -អនុក្រឹត្យលេខ ២៩០ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ២៩

៣១-១២-២០២១ -អនុក្រឹត្យលេខ ២៩១ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៣១

៣-១-២០២២ -អនុក្រឹត្យលេខ ០១ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៣៣

៣-១-២០២២ -អនុក្រឹត្យលេខ ០២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣៦

៤-១-២០២២ -អនុក្រឹត្យលេខ ០៣ អនក្រ.តត ស្តីពី ការដាក់ឱ្យចូលនិវត្តន៍មន្ត្រីនគរបាលជាតិកម្ពុជា ៤៣

៤-១-២០២២ -អនុក្រឹត្យលេខ ០៤ អនក្រ.តត ស្តីពី ការតែងតាំងឋានៈគ្រូនគរបាលជាតិកម្ពុជា ៤៥

៤-១-២០២២ -អនុក្រឹត្យលេខ ០៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៨

៤-១-២០២២ -អនុក្រឹត្យលេខ ០៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៩

៤-១-២០២២ -អនុក្រឹត្យលេខ ០៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥១

៤-១-២០២២ -អនុក្រឹត្យលេខ ០៨ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៥៣

៤-១-២០២២ -អនុក្រឹត្យលេខ ០៩ អនក្រ.តត ស្ដីពី ការបញ្ចូលក្របខ័ណ្ឌ និងប្រគល់ឋានន្តរស័ក្តិ នាយទាហាន ៥៤

៤-១-២០២២ -អនុក្រឹត្យលេខ ១០ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៥៥

៤-១-២០២២ -អនុក្រឹត្យលេខ ១១ អនក្រ.តត ស្ដីពី ការផ្ទេរ និងតែងតាំងមន្ត្រីរាជការ ៥៧

៥-១-២០២២ -អនុក្រឹត្យលេខ ១២ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៥៩

៥-១-២០២២ -អនុក្រឹត្យលេខ ១៣ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៦០

៦-១-២០២២ -អនុក្រឹត្យលេខ ១៤ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ ៦២

## ២~សេចក្ដីសម្រេច

៦-១-២០២២ -សេចក្ដីសម្រេចលេខ ០១ សសរ ស្ដីពី ការចាត់តាំងសមាសភាពគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ៦៣

១១-១-២០២២ -សេចក្ដីសម្រេចលេខ ០២ សសរ ស្ដីពី ការផ្លាស់ប្ដូរសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពត និងខេត្តកំពង់ស្ពឺ ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ៦៦

១៣-១-២០២២ -សេចក្ដីសម្រេចលេខ ០៣ សសរ ស្ដីពី ការកែសម្រួលសមាសភាពគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា ៦៨

## ៣~សារាចរ

១១-១-២០២២ -សារាចរលេខ ០១ សរ ស្ដីពី ការជំរុញការចាក់វ៉ាក់សាំងកូវីដ-១៩ និងការពង្រឹងការអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាល ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាពិសេស មេរោគបំប្លែងខ្លួនថ្មី ប្រភេទអូមីក្រុង ៧១

## ៤~សារាចរណែនាំ

១៤-១-២០២២ -សារាចរណែនាំលេខ ០១ សរណន ស្ដីពី ការកំណត់យកទិវានយោបាយឈ្នះឈ្នះ ថ្ងៃទី២៩ ខែធ្នូ ទៅក្នុងប្រតិទិនប្រចាំឆ្នាំ ដោយមិនឈប់សម្រាក ៧៤

# IV~ការងារបណ្ដាក្រសួង

## ១~ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៤-១-២០២២ -ប្រកាសលេខ ០០១ សហវ.ប្រក ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានគណៈកម្មការវិនិយោគសាធារណៈ ៧៥

## ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

១០-១-២០២២ -ប្រកាសលេខ ០០១ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដា ចាវ សុង ខូ អិលធីឌី បង្កើតរោងចក្រ ផលិតគ្រឿងបន្លាស់កង់ ៨០

| | | |
|---|---|---|
| ១០-១-២០២២ | -ប្រកាសលេខ ០០២ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វីកម៉ាក ហ្វេសិន (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ៨៣ |
| ១២-១-២០២២ | -ប្រកាសលេខ ០០៣ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឌីន លីង ហ្គាម៉ិន ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ៨៦ |
| ១៤-១-២០២២ | -ប្រកាសលេខ ០០៤ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស្កាវ៉េយ ឡៃធីង (ខេមបូឌា) អេនធើប្រាយ ឯ.ក បង្កើតរោងចក្រ ផលិតអំពូលភ្លើងលម្អ | ៨៩ |
| ១៤-១-២០២២ | -ប្រកាសលេខ ០០៥ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន កាន យ៉ាវ ស៊ីង ឡាយធីង ឯ.ក បង្កើតរោងចក្រ ផលិតអំពូលភ្លើង អំពូលលំអ និងគ្រឿងបង្គុំអំពូលគ្រប់ប្រភេទ | ៩២ |
| ១៧-១-២០២២ | -ប្រកាសលេខ ០០៦ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សូលធីម អេឡិចត្រូនីច (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្ភារៈបរិក្ខារអគ្គិសនី | ៩៥ |
| ១៨-១-២០២២ | -ប្រកាសលេខ ០០៧ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីន លី ហ្វាង (ខេមបូឌា) ហ្គាម៉ិន ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ៩៨ |
| ១៨-១-២០២២ | -ប្រកាសលេខ ០០៨ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ត្រេន អ៊ឺភែរ៉ឺល ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ១០១ |
| ១៨-១-២០២២ | -ប្រកាសលេខ ០០៩ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដេលី ណែឈរល ហ្វ៊ូតស្តាហ្វ បង្កើតរោងចក្រ ផលិតទឹកត្រី | ១០៤ |
| ១៨-១-២០២២ | -ប្រកាសលេខ ០១០ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេតា អ៊ឺភែរ៉ឺល ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ១០៧ |
| ១៩-១-២០២២ | -ប្រកាសលេខ ០១១ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៊ុយកៃ ភែកឃីជីង (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតថង់ប្លាស្ទិក កេសកាតុង ស្លាកសញ្ញាសម្លៀកបំពាក់ និងបោះពុម្ព | ១១០ |
| ១៩-១-២០២២ | -ប្រកាសលេខ ០១២ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជា ស៊ីណាត ហ្គាមេន ខូ អិលធីឌី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ១១៣ |
| ១៩-១-២០២២ | -ប្រកាសលេខ ០១៣ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដុង ភូ ក្រចេះ អភិវឌ្ឍន៍កៅស៊ូ បង្កើតរោងចក្រ កែច្នៃជ័រកៅស៊ូ | ១១៦ |
| ២៤-១-២០២២ | -ប្រកាសលេខ ០១៤ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន គ្លូប៊ល សឺបផ្លាយ ជេវរ៉ូង ឯ.ក បង្កើតរោងចក្រ ផលិតកាបូបគ្រប់ប្រភេទ | ១១៩ |
| ២៤-១-២០២២ | -ប្រកាសលេខ ០១៥ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីនឌីភេនដិនស៍ ខ្លូស៊ីង (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ១២២ |

# ព្រះរាជក្រម

នស/រកម/០១២២/០០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ដែលរដ្ឋសភាបាន អនុម័តកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែល ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់

# ស្តីពី

# វិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ .-**

មាត្រា១១ថ្មី មាត្រា១៤ថ្មី មាត្រា១៧ថ្មី និងមាត្រា២៦ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និងមាត្រា៤៧នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

**មាត្រា១១ .- ថ្មី(ពីរ)**

ក្រសួងពាណិជ្ជកម្មត្រូវបញ្ជូនបញ្ជីពាណិជ្ជកម្មនិងរាល់ឯកសារដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្មមួយច្បាប់ទៅតុលាការពាណិជ្ជកម្ម ដើម្បីជាឯកសារសម្រាប់យុត្តាធិការពាណិជ្ជកម្ម។

**មាត្រា១៤ .- ថ្មី(ពីរ)**

យ៉ាងតិចបំផុត១៥(ដប់ប្រាំ)ថ្ងៃមុនពេលចាប់ផ្តើមធ្វើពាណិជ្ជកម្មរបស់ខ្លួន ពាណិជ្ជករត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នៅកន្លែងដែលខ្លួនធ្វើអាជីវកម្ម។

ទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មមាននៅតាមមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ឬនៅទីកន្លែងផ្សេងទៀតតាមការកំណត់របស់ក្រសួងពាណិជ្ជកម្ម។

ពាណិជ្ជករត្រូវប្រគល់ទៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនូវប្រតិវេទន៍មួយ ដោយធ្វើជាពីរច្បាប់មានចុះហត្ថលេខាឬស្នាមមេដៃរបស់សាមីខ្លួន។

ប្រតិវេទន៍នេះត្រូវសរសេរលើលិខិតគំរូមួយដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មបានផ្តល់ឱ្យ។

ប្រតិវេទន៍ត្រូវថែងអំពី៖

១-នាមត្រកូលនិងនាមខ្លួនរបស់ពាណិជ្ជករនិងលេខនៃលិខិតអត្តសញ្ញាណរបស់ខ្លួន។

២-នាមប្រើប្រាស់ក្នុងពាណិជ្ជកម្មឬហស្សនាម។

៣-ថ្ងៃ-ខែ-ឆ្នាំ និងទីកន្លែងកំណើត អាសយដ្ឋានផ្ទាល់ខ្លួន លេខទូរស័ព្ទទំនាក់ទំនង និង/ឬអាសយដ្ឋានទំនាក់ទំនងអេឡិចត្រូនិក។

៤-សញ្ជាតិដើម ហើយក្នុងករណីដែលសាមីខ្លួនបានទទួលសញ្ជាតិមួយផ្សេងទៀតត្រូវបញ្ជាក់អំពីបែបបទនិងថ្ងៃ-ខែ-ឆ្នាំ ដែលបានទទួលសញ្ជាតិនេះ។

៥-កម្មវត្ថុអាជីវកម្ម អនុលោមតាមចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា ដែលបានដាក់ឱ្យប្រើប្រាស់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

៦-ទីកន្លែងធ្វើអាជីវកម្មនិងអាសយដ្ឋាន គ្រឹះស្ថានឬសាខានៃមូលនិធិពាណិជ្ជកម្មដែលមានទីតាំងនៅព្រះរាជាណាចក្រកម្ពុជា។

៧-ផ្លាកសញ្ញាពាណិជ្ជកម្មនៃគ្រឹះស្ថាន(ប្រសិនបើមាន)។

៨-លិខិតអត្តសញ្ញាណរបស់អ្នកតំណាងពេញសិទ្ធិដែលទទួលរ៉ាប់រងក្នុងការសុំចុះបញ្ជីពាណិជ្ជកម្ម។

៩-ទីតាំងគ្រឹះស្ថានពាណិជ្ជកម្មដែលអ្នកស្នើសុំបានធ្វើអាជីវកម្មពីមុនឬគ្រឹះស្ថានពាណិជ្ជកម្មដែលអ្នកស្នើសុំកំពុងធ្វើពាណិជ្ជកម្មនៅក្នុងរង្វង់សមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម។

១០-សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកស្នើសុំថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម។

១១-ក្នុងករណីចាំបាច់ លិខិតអនុញ្ញាតឱ្យប្រកបមុខរបរចំពោះមុខរបរណាឬចំពោះកម្មវត្ថុអាជីវកម្មណាដែលតម្រូវឱ្យមានសេចក្តីអនុញ្ញាត។

មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវចម្លងសេចក្តីក្នុងប្រតិវេទន៍ចូលក្នុងបញ្ជីពាណិជ្ជកម្មដោយប្រគល់ប្រតិវេទន៍នេះមួយច្បាប់ក្នុងចំណោមប្រតិវេទន៍ទាំងពីរច្បាប់ ជូនដល់អ្នកស្នើសុំចុះឈ្មោះដោយបញ្ជាក់នៅខាងក្រោមថា "បានចម្លងចូលបញ្ជីរួចហើយ"។

**មាត្រា១៧ ._ ថ្មី(ពីរ)**

គ្រប់ក្រុមហ៊ុនដែលមានសកម្មភាពពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីពាណិជ្ជកម្ម ទោះបីបែបបទនៃការបង្កើតនិងថិរវេលារបស់ក្រុមហ៊ុនទាំងនោះមានលក្ខណៈបែបណាក៏ដោយ។

ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនេះត្រូវធ្វើឡើងដោយបណ្ណាធិការឬអភិបាលនៃក្រុមហ៊ុននៅក្នុងខែនៃការបង្កើតក្រុមហ៊ុន និង១៥(ដប់ប្រាំ)ថ្ងៃមុនកាលបរិច្ឆេទបើកប្រតិបត្តិការពាណិជ្ជកម្ម។

អ្នកស្នើសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មត្រូវផ្តល់ដល់ទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនូវប្រតិវេទន៍ចំនួនពីរច្បាប់ មានចុះហត្ថលេខារបស់សាមីខ្លួនអ្នកស្នើសុំ ព្រមទាំងតម្កល់លក្ខន្តិកៈក្រុមហ៊ុនផង។

ប្រតិវេទន៍ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មផ្តល់គំរូជូននោះត្រូវចែងអំពី៖

១-នាមត្រកូលនិងនាមខ្លួនរបស់សមាជិកក្រុមហ៊ុន ថ្ងៃ-ខែ-ឆ្នាំនិងទីកន្លែងកំណើត ស្ថានភាពគ្រួសារ និងសញ្ជាតិ លេខទូរស័ព្ទទំនាក់ទំនង និង/ឬអាសយដ្ឋានទំនាក់ទំនងអេឡិចត្រូនិក។

២-ផ្លាកសញ្ញារបស់ក្រុមហ៊ុន(ប្រសិនបើមាន)។

៣-កម្មវត្ថុអាជីវកម្មអនុលោមតាមចំណាត់ថ្នាក់ស្តង់ដាវិស័យសេដ្ឋកិច្ចកម្ពុជាដែលបានដាក់ឱ្យប្រើប្រាស់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

៤-ទីកន្លែងទាំងឡាយដែលក្រុមហ៊ុនមានគ្រឹះស្ថានដើម សាខា ឬទីភ្នាក់ងារនៅព្រះរាជាណាចក្រកម្ពុជា។

៥-នាមត្រកូលនិងនាមខ្លួននៃសមាជិកឬតតិយជនដែលមានការអនុញ្ញាតឱ្យគ្រប់គ្រងចាត់ចែង ចុះចាត់ចែង និងចុះហត្ថលេខា ជំនួសមុខក្រុមហ៊ុន ថ្ងៃ-ខែ-ឆ្នាំ និងទីកន្លែងកំណើតនៃអ្នកទាំងនេះ។

៦-ដើមទុនរបស់ក្រុមហ៊ុន ប្រភពដើមទុន និងចំនួនទឹកប្រាក់ឬវត្ថុមានតម្លៃ ដែលផ្តល់ដោយសមាជិកភាគហ៊ុន ប្រសិនបើជាក្រុមហ៊ុនដោយភាគហ៊ុន។

៧-ថ្ងៃ-ខែ-ឆ្នាំ ដែលក្រុមហ៊ុននោះចាប់ផ្តើមនិងបញ្ចប់(ប្រសិនបើមាន)។

៨-ទ្រង់ទ្រាយក្រុមហ៊ុន។

៩-សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកស្នើសុំថាគ្មានទោសពៃរ៍ក្នុងរឿងព្រហ្មទណ្ឌឬការបាត់បង់សិទ្ធិ ឬការហាមឃាត់សិទ្ធិក្នុងកិច្ចការពាណិជ្ជកម្មឡើយ សម្រាប់ការពិនិត្យផ្ទៀងផ្ទាត់ជាក្រោយ។

**មាត្រា២៦ ... ថ្មី(ពីរ)**

យោងតាមប្រតិវេទន៍ជាលាយលក្ខណ៍អក្សរនិងរាល់ឯកសារតម្កល់ទុក មន្ត្រីចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជីនិងភ្ជាប់ជាមួយនូវសម្រង់ដែលមានចុះអត្តលេខសម្គាល់ការចុះបញ្ជីពាណិជ្ជកម្ម ហើយដែលអត្តលេខនេះមានតែមួយគត់សម្រាប់ការធ្វើសកម្មភាពពាណិជ្ជកម្មផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ វិញ្ញាបនបត្រនេះស្ថិតក្នុងលក្ខណៈជាបណ្តោះអាសន្នក្នុងថិរវេលា១(មួយ)ខែគិតចាប់ពីកាលបរិច្ឆេទដែលបានផ្តល់ជូន។ ក្នុងថិរវេលានេះ ប្រសិនបើគេឃើញថាជាប្រតិវេទន៍ក្លែងបន្លំឬផ្តល់ព័ត៌មានមិនពិតដោយទុច្ចរិតឬមានបណ្តឹងតវ៉ាដែលមានអានុភាពតាមច្បាប់ជាធរមាន ក្រោយពេលចុះបញ្ជី

ពាណិជ្ជកម្ម មន្ត្រីចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មអាចបដិសេធការចុះបញ្ជីនិងអាចលុបចោលអត្តលេខសម្គាល់ដែលបានចុះក្នុងបញ្ជីពាណិជ្ជកម្មនោះ។

មន្ត្រីចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មដែលផ្តល់វិញ្ញាបនបត្រក្លែងបន្លំដោយដឹងហេតុផលសព្វគ្រប់ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**មាត្រា៤៧ .- ថ្មី**

រាល់ពាណិជ្ជករឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្ម មានកាតព្វកិច្ចអនុវត្តវិធានគណនេយ្យនិងសវនកម្មដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

រាល់ពាណិជ្ជករឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងកថាខណ្ឌខាងលើ ត្រូវទទួលខុសត្រូវតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រាពីរ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ១៤រោច ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០២២

នស/រកម.០១២២.០០៥

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០០១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

**ជាកិច្ចបច្ឆាមរណៈ**

ចំពោះឯកឧត្តម **គួ សាគីន**
ដែលបានទទួលមរណភាព

នរស. ២២០១.០០១
បានប្រទាប់ព្រះរាជលញ្ឆករហើយ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែមករា ឆ្នាំ២០២២*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ : ០០១/២២ រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២២
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ **គង់ សំអុល**
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** និយ័តកម្ម តម្លើង ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ដល់លោក **ឡាយ សំអឿន** ពីឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ មកជាឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៤ នៃក្របខ័ណ្ឌ មន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៦៣. ៤៤០១.០០៤

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០២២*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : និយ័តកម្ម តម្លើងក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ជូនលោក **ខណ្ណរ៉ា ម៉ាប់** ពីឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៣ នៃក្របខ័ណ្ឌមន្ត្រីក្រមការ មកជាឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ១ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៧៥ល.២២០១.០០៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០២២*

នសីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួល សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង និងផ្តល់ឋានៈ ឯកឧត្តម **សូ មុនីរក្សា** ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ២ ជានាយកសាលាជាតិ រដ្ឋបាលមូលដ្ឋាន "ស.ជ.រ.ម" នៃក្រសួងមហាផ្ទៃ មានបុព្វសិទ្ធស្មើអគ្គនាយក។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

[illegible].២២០១.០០៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០០៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ដល់ វរសេនីយ៍ឯក **អ៊ុក ស្រីមុំ** អត្តលេខ ០៥៩៦៥២ នាយទាហានថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នរោត្តម សីហមុនី

ចាសណ. ២២០១.០០៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/០១២២/០០៦

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង និងផ្តល់ឋានៈ ឯកឧត្តម **ឯម ប៊ុនសាត** ជាជំនួយការអមក្រសួងបរិស្ថាន មានឋានៈស្មើអគ្គនាយក។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

ចារណ.២២០១.០០៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានថ្វាយជូនសម្តេចព្រះមហាក្សត្រ ដើម្បីលង់ព្រះហស្តលេខា? 

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/ ០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តាំងស៊ប់ ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដល់មន្ត្រីរាជការ ០៦ រូប ចាប់ពីថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០២១ ៖

| | | |
|---|---|---|
| ១-លោក | **កែ ប៊ុនធឿន** | អនុមន្ត្រី ថ្នាក់លេខ ៥ |
| ២-លោក | **ស្រ៊ុន បញ្ញារិទ្ធិ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៥ |
| ៣-លោកស្រី | **លី សុខនី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៥ |
| ៤-លោក | **ឈោង អង្គារ៉ា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៥ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៥- លោក **អ៊ុំ ប៉ោស្រ៊ី** មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤

៦- លោកស្រី **យក់ សុគន្ធស្រីរតន៍** មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នស.រកត.០១២២.០០៧

នសីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០២២*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ដល់សប្បុរសជន ២៦រូប៖

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- មេធាវី ហួន វិទ្យា
២- លោក ច័ន្ទ ទិត្យរ៉ាម៉ូ
៣- លោក កុយ កិត្យានិម្មិត
៤- លោក យាប គង្គា
៥- លោក នាង ចាន់ណាក់
៦- លោកជំទាវ លី សុគន្ធារី រៀនវុទ្ធី
៧- លោក ឡឹក ផាន់ណា
៨- លោក ទៀ ស៊ុនឆាយ
៩- លោក ឡាយ ឆាយម៉េង
១០- ឧត្តមសេនីយ៍ត្រី ឈីន តាយ អត្តលេខ ៨២៩៩៦

ខ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ព្រះគ្រូមង្គលចរិយាវុឌ្ឍី សារ៉ាត់ សេងវឌ្ឍន៍
២- ឯកឧត្តម ឧត្តមសេនីយ៍ឯក យៀង ណាត អត្តលេខ ៣៤០៣៧
៣- ឧត្តមសេនីយ៍ទោ ឡុង ពិជ អត្តលេខ ៨៣៣៨៣
៤- ឧត្តមសេនីយ៍ទោ ស៊ិន ណារិទ្ធិ អត្តលេខ ០៣២២៨៣
៥- លោក អ៊ុំ វិណារ៉ា
៦- លោក ថា ម៉ាទីន

គ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១- លោក រស់ សំបុក
២- អ្នកស្រី ឈុន សុគន្ធ
៣- លោក ហេង ស្រេង
៤- លោក រឿន ធីតា
៥- អ្នកស្រី ឡុង សំរេច
៦- លោក ម៉ូវ ម៉េង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៧- លោក វ៉ាត សុគន្ធា ៩- ឧបាសិកា សូ សុខន

៨- លោក គឹម ហ៊ុនអា ១០- ឧបាសិកា សូ ស្រីពៅ

នស.រកត.០១២២.០០៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០០៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **នាគ ស៊ីនសាន** (NIE XINSHAN) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៩ នៅតំបន់ស្វយ័តស៊ីនជាំង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **នាគ សំគសាន** ( NIE SHUOSHAN )។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស.២២០១.០០៩

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/ ០៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

## ត្រាស់បង្គាប់

ផ្តល់គោរមងារ :

ឯកឧត្តម ហេង ឆ័ន់ដា

ជា

ឧកញ៉ា

៣ខណ. ២២០១. ០៧០

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២២

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០៧៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

## ត្រាស់បង្គាប់

ផ្តល់គោរមងារ :

ឯកឧត្តម តែ ឡូរិន

ជា

ឧកញ៉ា

នរោត្តម សីហមុនី

៣៩៩. ២៤០១. ០៧៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២២

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/ ០៦៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

## ត្រាស់បង្គាប់

ផ្តល់គោរមងារ :

ឯកឧត្តម **ឡុង លាង**

ជា

**ឧកញ៉ា**

៣៥ល. ២២០១. ០៦៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២២

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

## ត្រាស់បង្គាប់

ផ្តល់គោរមងារ :

លោកជំទាវ ខេព ភួលាប

ជា

**ឧកញ៉ា**

៦៧៥៧.២២០១.០១៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/ ០១៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំងមុខតំណែងលោកជំទាវ **សុខ្ខ សុម៉ាលី** **ជាអនុរដ្ឋលេខាធិការ** នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស.២២០១.០១៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសល្យបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/ ០១៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ថាង យ៉ូលាំង** (TANG, YULIANG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៨៨ នៅខេត្ត Hubei សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស.២២០១.០១៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២២/០៦

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** តែងតាំង និងផ្តល់ឋានៈគ្រូនគរបាលជាតិដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ១២ រូប ជាគ្រូនគរបាលជាតិ **ឧត្តមកម្រិត១ ថ្នាក់លេខ២** មានឋានៈស្មើ **អគ្គនាយក** នៃក្រសួងមហាផ្ទៃ ៖

១- លោកឧត្តមសេនីយ៍ឯក **ទ្រី គីមសេង** អត្តលេខ ០៧៩៧
២- លោកឧត្តមសេនីយ៍ឯក **រស់ សារិទ្ធ** អត្តលេខ ០៨០១
៣- លោកឧត្តមសេនីយ៍ឯក **ផន សុភា** អត្តលេខ ០៩៩០
៤- លោកឧត្តមសេនីយ៍ឯក **ទ្រី ចន្ធី** អត្តលេខ ០៤៨៩២
៥- លោកឧត្តមសេនីយ៍ឯក **កែវ មុន្នីរ័ត្ន** អត្តលេខ ០៥៨៣៧
៦- លោកឧត្តមសេនីយ៍ឯក **ឆេង ពន្លក** អត្តលេខ ៣០៣៦០
៧- លោកឧត្តមសេនីយ៍ឯក **អេឆក សុភា** អត្តលេខ ៧៤៦៧៧
៨- លោកឧត្តមសេនីយ៍ឯក **សាយ បាន** អត្តលេខ ៧៥៥៤៤
៩- លោកឧត្តមសេនីយ៍ទោ **នុត សុខលី** អត្តលេខ ០៤៩០០
១០- លោកឧត្តមសេនីយ៍ទោ **ឡេង បូរាណា** អត្តលេខ ០៦០២៤
១១- លោកឧត្តមសេនីយ៍ទោ **ជួប ស៊ីនួន** អត្តលេខ ២០៤៣៧
១២- លោកឧត្តមសេនីយ៍ទោ **រស់ រក្សា** អត្តលេខ ៥៤៩៦៨ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នរោត្តមសីហមុនី

ពរស.៤៥០១.០៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ីន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ៤៦២/០០១/២០២២
ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២២

**សេចក្តីសម្រេច**
លេខ : ២១៦/០០១/២០២២ កបធ.ច
ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ មាត្រា ២៧ ថ្មី មាត្រា ២៨ មាត្រា ៣១ និងមាត្រា ៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញសេចក្តីសម្រេចលេខ ០០១ គ.ជ.ប ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២២ របស់ឈ្មោះ **ដួង វិចិត្រ** ជាអ្នកប្តឹងផ្ទាល់ និងជាអ្នកតំណាងទទួលសិទ្ធិពីឈ្មោះ **អ៊ុន សុគន្ធី** ឈ្មោះ **ដួង ចិន្តាមុនី** ឈ្មោះ **ដួង វិរៈ** និងឈ្មោះ **ដួង វិសាល** ប្តឹងតវ៉ានឹងសេចក្តីសម្រេចលេខ ០០១ គ.ជ.ប ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងប្តឹងទាមទារសិទ្ធិបោះឆ្នោតនិងសញ្ជាតិជាប្រជាពលរដ្ឋខ្មែរ
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២២ របស់ឈ្មោះ **អ៊ុន សុគន្ធី** ឈ្មោះ **ដួង ចិន្តាមុនី** ឈ្មោះ **ដួង វិរៈ** និងឈ្មោះ **ដួង វិសាល** ជូនឈ្មោះ **ដួង វិចិត្រ** ដើម្បីធ្វើជាអ្នកតំណាងក្នុងការដាក់ពាក្យបណ្តឹង និងដោះស្រាយបណ្តឹងតវ៉ានៅក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៤៣ គ.ជ.ប ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្តម **មាន សទិ** ឯកឧត្តម **សោម សូរីដា** ឯកឧត្តម **តុប ឫទ្ធី** និងលោក **ភាព វិរៈ** មកបំភ្លឺចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៤៥ គ.ជ.ប ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្តម **មាន សទិ** ឯកឧត្តម **សោម សូរីដា** ឯកឧត្តម **តុប ឫទ្ធី** និងលោក **ភាព វិរៈ** ដើម្បីមកបំភ្លឺក្នុងសវនាការជំនុំជម្រះជាសាធារណៈលើពាក្យបណ្តឹងរបស់ឈ្មោះ **ដួង វិចិត្រ** ជាអ្នកប្តឹងផ្ទាល់ និងជាអ្នកតំណាងទទួលសិទ្ធិពីឈ្មោះ **អ៊ុន សុគន្ធី** ឈ្មោះ **ដួង ចិន្តាមុនី** ឈ្មោះ **ដួង វិរៈ** និងឈ្មោះ **ដួង វិសាល**
- បានឃើញកំណត់ហេតុសួរយកចម្លើយរបស់ឈ្មោះ **ដួង វិចិត្រ** កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ ចំពោះមុខមន្ត្រីស៊ើបអង្កេតរបស់ក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុបំភ្លឺរបស់ឯកឧត្តម **មាន សទិ** ឯកឧត្តម **សោម សូរីដា** ឯកឧត្តម **តុប ឫទ្ធី** និងលោក **ភាព វិរៈ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ ភ្ជាប់ដោយសារណាចំនួន ០១ ច្បាប់ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២
- បានឃើញកំណត់ហេតុ និង របាយការណ៍ចុះស៊ើបអង្កេតរបស់មន្ត្រីស៊ើបអង្កេតរបស់ក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ នៅសាលាសង្កាត់ផ្សារចាស់ និងប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ផ្សារចាស់
- ឈ្មោះ **ដួង វិចិត្រ** ជាអ្នកប្តឹងផ្ទាល់ និងជាអ្នកតំណាងទទួលសិទ្ធិពីឈ្មោះ **អ៊ុន សុគន្ធី** ឈ្មោះ **ដួង ចិន្តាមុនី** ឈ្មោះ **ដួង វិរៈ** និងឈ្មោះ **ដួង វិសាល** អវត្តមាននាពេលសវនាការដោយគ្មានមូលហេតុ

## ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា ការមិនចូលរួមក្នុងសវនាការរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃក្រុមប្រឹក្សាធម្មនុញ្ញ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ លើសំណុំរឿងលេខ ៤៦២/០០១/២០២២ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២២ របស់ឈ្មោះ **ដួង វិចិត្រ** ជាអ្នកប្ដឹងផ្ទាល់ និងជាអ្នកតំណាងទទួលសិទ្ធិពីឈ្មោះ **អ៊ុន សុគន្ធី** ឈ្មោះ **ដួង ចិន្តាមុនី** ឈ្មោះ **ដួង វិរៈ** និងឈ្មោះ **ដួង វិសាល** ដោយគ្មានមូលហេតុ ត្រូវចាត់ទុកថា ជាការបង្ហាញឆន្ទៈបោះបង់បណ្ដឹងចោល ដូចនេះ ក្រុមប្រឹក្សាជំនុំជម្រះនៃក្រុមប្រឹក្សាធម្មនុញ្ញ មិនលើកបណ្ដឹងយកមកពិនិត្យឡើយ។

## សម្រេច

**មាត្រា ១**.- ប្រានចោលបណ្ដឹងចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២២ របស់ឈ្មោះ **ដួង វិចិត្រ** ជាអ្នកប្ដឹងផ្ទាល់ និងជាអ្នកតំណាងទទួលសិទ្ធិពីឈ្មោះ **អ៊ុន សុគន្ធី** ឈ្មោះ **ដួង ចិន្តាមុនី** ឈ្មោះ **ដួង វិរៈ** និងឈ្មោះ **ដួង វិសាល** ។

**មាត្រា ២**.- សេចក្ដីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។/.

ថ្ងៃព្រហស្បតិ៍ ១០រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជាក្រុមប្រឹក្សាជំនុំជម្រះ**
**ប្រធាន**

ហត្ថលេខា និងត្រា

កិត្តិនីតិកោសលបណ្ឌិត **អ៊ឹម ឈុនលឹម**

ក្រុមប្រឹក្សាធម្មនុញ្ញ
ទទួល
លេខ ៤៦២/០០១/២០២២
ថ្ងៃ ២៧/០១/២០២២ ម៉ោង ១៤:៣០
បញ្ជូន ន.ឡាច់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្តឹង**

ខ្ញុំបាទឈ្មោះ **ដួង វិចិត្រ** ភេទប្រុស កើតថ្ងៃទី 18 ខែតុលា ឆ្នាំ 1955 បានចូលបម្រើជាតិនៅឆ្នាំ 1981 មានសៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ 010304806 មុខងារ មន្ត្រីនគរបាលចូលនិវត្តន៍ ជាដើមបណ្តឹង និងតំណាងទទួលសិទ្ធិពីប្រជាពលរដ្ឋចំនួន 04 រូប មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ផ្ទះលេខ 24E0 ផ្លូវលេខ 15 ភូមិទី 6 សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងស្នាក់នៅមួយកន្លែងទៀត ផ្ទះលេខ 1029B ផ្លូវ 30C ភូមិទ្រា2 សង្កាត់ស្ទឹងមានជ័យទី1 ខណ្ឌមានជ័យ រាជធានីភ្នំពេញ ទូរស័ព្ទលេខ 012 851 797 ។

**សូមគោរពជូន**
**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**
*សូមទានជ្រាប ។*

**កម្មវត្ថុ:** - ប្តឹងតវ៉ា និងសេចក្តីសម្រេចលេខ 001 គ.ជ.ប ចុះថ្ងៃទី 18 ខែមករា ឆ្នាំ 2022 របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។
- ប្តឹងទាមទារសិទ្ធិបោះឆ្នោត និងសញ្ជាតិជាប្រជាពលរដ្ឋខ្មែរ ។

**មូលហេតុ:** ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសម្រេចរក្សាការលប់ឈ្មោះប្រជាពលរដ្ឋចំនួន 05 រូប ចេញបញ្ជីចុះឈ្មោះបោះឆ្នោតឆ្នាំ 2021 ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងមូលហេតុខាងលើ ខ្ញុំបាទសូមជម្រាប **ឯកឧត្តម** ជូនជ្រាបថា ៖ ដោយក្រុមគ្រួសារខ្ញុំបាទមានមុខរបររកទទួលទានជាប្រចាំថ្ងៃនៅផ្សារចាស់ មានទីលំនៅផ្ទះលេខ 24E0 ផ្លូវ 15 ភូមិទី 6 សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ តាំងពីឆ្នាំ 1981 មកម្ល៉េះ ដល់ឆ្នាំ 2005 បានលក់ផ្ទះ (មិនទាន់ធ្វើលិខិតផ្ទេរសិទ្ធិកាត់ប្លង់រឹងទេ) ហើយក្រុមគ្រួសារខ្ញុំបាទចំនួន 05 នាក់ មកស្នាក់នៅផ្ទះលេខ 1029B ផ្លូវ 30C ភូមិទ្រា2 សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ តែបានចុះឈ្មោះបោះឆ្នោតនៅសង្កាត់ផ្សារចាស់រហូតមកដល់ឆ្នាំ 2020 ។ ដល់ថ្ងៃទី 23 ខែតុលា ឆ្នាំ 2020 ទើបបានធ្វើលិខិតផ្លាស់ប្តូរមកនៅសង្កាត់ស្ទឹងមានជ័យទី 1 ដើម្បីធ្វើកម្មសិទ្ធិផ្ទះតែពួកយើងខ្ញុំទាំង 05នាក់ មិនបានចុះឈ្មោះបោះឆ្នោតថ្មីក្នុង ឃុំ/សង្កាត់ នៃរាជធានី/ខេត្តណាផ្សេងទៀតទេ ហេតុអ្វីទើបតែបាន គ.ជ.ប លប់ឈ្មោះឆ្នាំ 2021 មិនបានពិនិត្យឈ្មោះព្រោះសម័យកូវីដ-១៩ ។ ពេលដល់ឆ្នាំ 2023 ខ្ញុំបាទ និងប្រជាពលរដ្ឋ 04 រូប និងផ្ទេរចេញពីសង្កាត់ផ្សារចាស់មកចុះឈ្មោះបោះឆ្នោតថ្មីនៅសង្កាត់ស្ទឹងមានជ័យទី1 ខណ្ឌមានជ័យ រាជធានីភ្នំពេញ វិញហើយ (កុំឱ្យផ្តោះសិទ្ធិឆ្នាំ 2022 មិនបានបោះឆ្នោត) ។

អាស្រ័យហេតុដូចបានជម្រាប សូម **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតប្រធានក្រុមប្រឹក្សាធម្មនុញ្ញ** អាណិតមេត្តាសន្តោសប្រណី អនុញ្ញាត រក្សាទុកឈ្មោះខ្ញុំបាទ និងប្រជាពលរដ្ឋ 04រូបទៀត ដូចមានបញ្ជីរាយនាមជូនភ្ជាប់មកជាមួយ អោយបានសិទ្ធិបោះឆ្នោតនៅសង្កាត់ផ្សារចាស់ឆ្នាំ 2022 ដើម្បីជ្រើសរើសឃុំ/សង្កាត់ ដោយសេចក្តីអនុគ្រោះ ។

សូមគោរពជូនពរ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតប្រធានក្រុមប្រឹក្សាធម្មនុញ្ញ** ទទួលបានពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ថ្ងៃសៅរ៍ ៥រោច ខែបុស្ស ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមករា ឆ្នាំ ២០២២

**ហត្ថលេខា ឬស្នាមមេដៃ**



**ជួន វិចិត្រ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៩០ អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការផ្ទេរឥណទានថវិកា**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃ សុក្រ ១១កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃ អង្គារ ១៥កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១២ ២០៧ ០០០ ០០០ រៀល (ដប់ពីរប៊ីលានពីររយប្រាំពីរលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦២ (អត្ថប្រយោជន៍សង្គម) ជូនទីស្ដីការគណៈរដ្ឋមន្ត្រី សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។

**មាត្រា២ .-**

**មាត្រា ១ :** តម្លើងឋានន្តរសក្តិ **វរសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **ឆុយ ថិធូ** អត្តលេខ ៧៨២៦៩ នាយនគរបាលជាន់ខ្ពស់ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៤ កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែមករា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០១ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការចាត់តាំងសមាសភាពគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទាន ដល់ការរីកសាយភាយអាវុធមហាប្រល័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- បានឃើញអនុក្រឹត្យលេខ១៤២ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- បានឃើញអនុក្រឹត្យលេខ០៥ អនក្រ.បក ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

## សម្រេច

**ប្រការ ១.**_

ចាត់តាំងសមាសភាពគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ហៅកាត់ថា **គ.ស.ហ.** ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១- **សម្តេចក្រឡាហោម ស ខេង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២- ឯកឧត្តម **ជា ចាន់តូ** | អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា | អនុប្រធានប្រចាំការ |
| ៣- ឯកឧត្តម **កើត រិទ្ធ** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤- ឯកឧត្តម **ទី ច័ន្ទ្រផល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៥- ឯកឧត្តម **ជីវ សុខហាក់** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៦- ឯកឧត្តម **រស់ សីលវ៉ា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧- ឯកឧត្តម **ញ៉ឹម ខេមរា** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៨- ឯកឧត្តម នាយឧត្តមសេនីយ៍ **សាទ សុខ** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៩- ឯកឧត្តម **សុខ សុភ័ក្ត្រ** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០- ឯកឧត្តម **ភាន ច័ន្ទមេត្តា** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១១- ឯកឧត្តម **នុត ច័ន្ទសុខា** | រដ្ឋលេខាធិការប្រចាំការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២- ឯកឧត្តម **នេត្រ ភក្ត្រា** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៣- ឯកឧត្តម **ថេង ច័ន្ទសង្វារ** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៤- ឯកឧត្តម **ស្រ៊ិន សុវណ្ណា** | ឧបការីអង្គភាពប្រឆាំងអំពើពុករលួយ | សមាជិក |
| ១៥- ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ១៦- ឯកឧត្តម នាយឧត្តមសេនីយ៍ **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៧- ឯកឧត្តមនាយឧត្តមសេនីយ៍ **គៀត ច័ន្ទថារិទ្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ១៨- ឯកឧត្តមនាយឧត្តមសេនីយ៍ **គង សុខន** | អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | សមាជិក |
| ១៩- ឯកឧត្តម **គុណ ញឹម** | អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ២០- ឯកឧត្តម **គង់ វិបុល** | អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២១- ឯកឧត្តម **ម៉ី វ៉ាន់** | អគ្គលេខាធិការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | សមាជិក |

| | | |
|---|---|---|
| ២២- ឯកឧត្តមនាយឧត្តមសេនីយ៍ **មាស ទីរិទ្ធ** | អគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | សមាជិក |
| ២៣- ឯកឧត្តម **រស់ តិរុណា** | អគ្គលេខាធិការ នៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ២៤- ឯកឧត្តម **ស៊ុំ សន្និសិទ្ធ** | ប្រធានក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | សមាជិក |
| ២៥- ឯកឧត្តម **ឡូរី ត្រាយ** | អនុប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម | សមាជិក |
| ២៦- ឯកឧត្តម **រិទ្ធ អារុណនិត្យា** | អគ្គនាយកនៃអគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការផ្ទៃក្នុង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២៧- លោក **អ៊ូ សុផល** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ២៨- លោកជំទាវ **សាយ សំអាត** | ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | លេខាធិការ |

**ប្រការ ២.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៥កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ មករា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០២.៩សរ........

**សេចក្តីសម្រេច**

**ស្តីពី**

**ការផ្លាស់ប្តូរសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពត និងខេត្តកំពង់ស្ពឺ ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត
- យោងសេចក្តីណែនាំលេខ ០១ សណន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ក្នុងការបំពេញបេសកកម្ម ដើម្បីត្រួតពិនិត្យ និងគាំទ្រកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

**សម្រេច**

**ប្រការ១ .-**

ត្រូវបានផ្លាស់ប្តូរ ឯកឧត្តម **ហុង ម៉េងហួ** អនុរដ្ឋលេខាធិការ ក្រសួងផែនការ ពីសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពត មកជាសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន **ខេត្តកំពង់ស្ពឺ** ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។

**ប្រការ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋបាលខេត្តកំពត រដ្ឋបាលខេត្តកំពង់ស្ពឺ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៩ កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ២០២២

**អប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>*កន្លែងទទួល:*</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:០៣.សសរ**

**សេចក្តីសម្រេច**

**ស្តីពី**

**ការកែសម្រួលសមាសភាពគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការកែសម្រួលនិងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៦៧១ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៤ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- យោងសេចក្តីសម្រេចលេខ៩៦ សសរ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សម្រេច**

**ប្រការ១.-**

ត្រូវបានកែសម្រួលសមាសភាពគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា (គ.អ.ឆ.ក.) ដែលមានដូចខាងក្រោមៈ

**១-សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** **ប្រធានកិត្តិយស**

២-ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធាន

៣-ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន អនុប្រធាន

៤-ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អនុប្រធានអចិន្ត្រៃយ៍

៥-ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ិង ថូរ៉ាក់ស៊ី** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជា រដ្ឋលេខាធិការប្រចាំការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៦-ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ សមាជិក

៧-ឯកឧត្តមនាយឧត្តមសេនីយ៍ **ឯល វ៉ាន់សារ៉ាត** រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

៨-ឯកឧត្តម **ទី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៩-ឯកឧត្តម **យុទ្ធ ភូថង** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១០-ឯកឧត្តម **តោគ សុវណ្ណារិទ្ធ** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សមាជិក

១១-ឯកឧត្តម **ហូ វិចិត្រ** រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល សមាជិក

១២-ឯកឧត្តម **ឥន់ វ៉ាន់ថារ៉ា** រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម សមាជិក

១៣-ឯកឧត្តម **លឹម ស៊ីដេនីន** រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

១៤-ឯកឧត្តម **ហ៊ូ តាំងអេង** រដ្ឋលេខាធិការក្រសួងផែនការ សមាជិក

១៥-លោកជំទាវវេជ្ជបណ្ឌិត **យក់ សម្បត្តិ** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិកា

១៦-ឯកឧត្តម **សុខ ចិន្តាសោភា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជា អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

១៧-ឯកឧត្តមនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ សមាជិក

១៨-ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១៩-ឯកឧត្តម **គួច ចំរើន** អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ សមាជិក

២០-ឯកឧត្តម **ម៉ៅ ធនិន** អភិបាលនៃគណៈអភិបាលខេត្តកំពត សមាជិក

២១-ឯកឧត្តម **សោម ពិសិដ្ឋ** អភិបាលនៃគណៈអភិបាលខេត្តកែប សមាជិក

២២-លោកជំទាវ **មិថុនា ភូថង** អភិបាលនៃគណៈអភិបាលខេត្តកោះកុង សមាជិកា

២៣-ឯកឧត្តម **ឃុន បូរិន្ទ** តំណាងគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ សមាជិក

| | | |
|---|---|---|
| ២៤-ឯកឧត្តម **ឆេព ធន** | តំណាងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | សមាជិក |
| ២៥-ឯកឧត្តម **ទ៉ាន់ មុនីនាថ** | តំណាងក្រសួងបរិស្ថាននិងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | សមាជិក |
| ២៦-ឯកឧត្តម **ឆាយ ឫទ្ធិសែន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២៧-ឯកឧត្តម **ប៉ែន សុផល** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក. | សមាជិក។ |

**ប្រការ២.-**

គ.អ.ឆ.ក. មានរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ០១ សរ

**សារាចរ**

**ស្តីពី**

**ការជំរុញការចាក់វ៉ាក់សាំងកូវីដ-១៩ និងការពង្រឹងការអនុវត្តវិធានការសុវត្ថិភាព ផ្នែកសុខាភិបាល ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាពិសេស មេរោគបំប្លែងខ្លួនថ្មី ប្រភេទអូមីក្រុង**

កន្លងទៅនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ សំដៅការពារសុខភាព និងអាយុជីវិតរបស់ប្រជាជន រហូតសម្រេចបាននូវការបើកដំណើរការប្រទេសជាតិពេញលេញឡើងវិញលើគ្រប់វិស័យ និងសម្រេចបិទបញ្ចប់ "**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ**" កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១។ ការសម្រេចបាននូវវឌ្ឍនភាពដ៏ល្អប្រសើរទាំងនេះ គឺដោយសាររាជរដ្ឋាភិបាលបានដាក់ចេញ និងបានអនុវត្តយ៉ាងសកម្មនូវគោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ ដែលជាយុទ្ធសាស្ត្រគន្លឹះដ៏សំខាន់មួយ និងជាខ្សែក្រវាត់ការពារទី១ ដើម្បីបង្កើតឱ្យបាននូវភាពស៊ាំសហគមន៍ទប់ទល់នឹងមេរោគកូវីដ-១៩ ដែលគិតមកទល់ពេលនេះ ព្រះរាជាណាចក្រកម្ពុជាសម្រេចបានការចាក់វ៉ាក់សាំងជូនប្រជាជនដែលមានអាយុចាប់ពី ៥ ឆ្នាំឡើងទៅ បានប្រមាណជិត ៩០% ធៀបនឹងគោលដៅប្រមាណ ១៦ លាននាក់ ក្នុងនោះ មានប្រជាជនប្រមាណ ៤ លាននាក់ បានទទួលការចាក់វ៉ាក់សាំងដូសជំរុញ។ ជាមួយគ្នានេះ, ការចូលរួមប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់ប្រជាជនគ្រប់ៗរូប, គ្រួសារនីមួយៗ, សហគមន៍ និងពីគ្រប់តួអង្គដែលមានការពាក់ព័ន្ធទាំងអស់ ក្នុងការអនុវត្តបានយ៉ាងខ្ជាប់ខ្ជួន និងត្រឹមត្រូវ នូវវិធានការនានាដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ជាពិសេស វិធានការសុវត្ថិភាពផ្នែកសុខាភិបាល ជាអាទិ៍ ការពាក់ម៉ាស ការធ្វើអនាម័យ និងការរក្សាគម្លាតសុវត្ថិភាព ក៏ជាកត្តាគន្លឹះក្នុងការធ្វើឱ្យសម្រេចបាននូវការបើកដំណើរការប្រទេសជាតិពេញលេញឡើងវិញលើគ្រប់វិស័យ និងសម្រេចបិទបញ្ចប់ "**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ**" ផងដែរ។

ខណៈដែលប្រទេសជាតិត្រូវបើកដំណើរការពេញលេញឡើងវិញលើគ្រប់វិស័យ ហើយស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា ស្ថិតក្នុងសភាពធូរស្រាល និងអាចគ្រប់គ្រងវិញបាន **រាជរដ្ឋាភិបាល** ពិនិត្យឃើញថាប្រជាជនមួយចំនួននៅតែមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន បានពេញលេញនៅឡើយ និងចំនួនប្រជាជនដែលទទួលបានការចាក់វ៉ាក់សាំងដូសជំរុញ នៅមានចំនួនតិចតួចនៅឡើយ បើធៀបទៅនឹង

ចំនួនប្រជាជនដែលបានចាក់វ៉ាក់សាំងដូសមូលដ្ឋានរួច ហើយទន្ទឹមនេះ ប្រជាជនមួយចំនួនហាក់បាន និងកំពុងមានការធ្វេសប្រហែសក្នុងការអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាល ជាពិសេស វិធានការ "**៣កុំ ៣ការពារ**" ដែលអាចជាកត្តាប្រឈមនឹងការផ្ទុះឆ្លងរាលដាលមេរោគកូវីដ-១៩ ក្នុងសហគមន៍ជាថ្មីម្តងទៀត។ ទន្ទឹមនេះ, ព្រះរាជាណាចក្រកម្ពុជាក៏បានចាប់ផ្តើមរកឃើញជាបន្តបន្ទាប់នូវវត្តមានមេរោគបំប្លែងខ្លួនថ្មី ប្រភេទអូមីក្រុង ក្នុងសហគមន៍ផងដែរ។

ផ្អែកលើបរិបទខាងលើនេះ ជាពិសេស ដើម្បីទប់ទល់នឹងការឆ្លងរាលដាលនៃមេរោគបំប្លែងខ្លួនថ្មី ប្រភេទអូមីក្រុង ក្នុងសហគមន៍, **រាជរដ្ឋាភិបាល** សូមធ្វើការណែនាំដល់ គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស, គណៈអភិបាលរាជធានី-ខេត្ត និងយន្តការដែលមានការពាក់ព័ន្ធផ្សេងទៀត ព្រមទាំងប្រជាជនទូទៅ ដូចខាងក្រោម៖

ទី១-គណៈអភិបាលរាជធានី-ខេត្តទាំងអស់ ដោយសហការជាមួយគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស និងយន្តការដែលមានការពាក់ព័ន្ធ ត្រូវជំរុញ និងបង្កើនល្បឿននៃការចាក់វ៉ាក់សាំងកូវីដ-១៩ ទាំងដូសមូលដ្ឋាន ទាំងដូសជំរុញ ដែលជាខ្សែក្រវាត់ការពារទី១ និងជាយុទ្ធសាស្ត្រគន្លឹះរបស់រាជរដ្ឋាភិបាល ក្នុងសមរភូមិប្រយុទ្ធនឹងជំងឺកូវីដ-១៩ ជូនដល់ប្រជាជននៅក្នុងភូមិសាស្ត្រស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ឱ្យសម្រេចបានឆាប់រហ័ស ដើម្បីធានាឱ្យបាននូវភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយសំដៅទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការឆ្លងរាលដាលនៃមេរោគបំប្លែងខ្លួនថ្មី ប្រភេទអូមីក្រុង។

ទី២-គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ត្រូវបន្តពង្រឹងយន្តការតាមដាន និងត្រួតពិនិត្យរបស់ខ្លួនលើវឌ្ឍនភាពនៃការអនុវត្តការងារចាក់វ៉ាក់សាំងកូវីដ-១៩ ប្រចាំថ្ងៃ ទាំងសម្រាប់ក្របខណ្ឌរាជធានី-ខេត្តនីមួយៗដាច់ដោយឡែកពីគ្នា ទាំងសម្រាប់ក្របខណ្ឌទូទាំងប្រទេស ព្រមទាំងត្រូវពង្រឹងយន្តការឆ្លើយតបឱ្យបានទាន់ពេលវេលា ទាក់ទងនឹងការអនុវត្តការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនប្រជាជនជាក់ស្តែងនៅតាមមូលដ្ឋាន ជាពិសេស ការសម្របសម្រួលក្រុមគ្រូពេទ្យចាក់វ៉ាក់សាំងឱ្យត្រូវទៅនឹងស្ថានភាពជាក់ស្តែងនៅក្នុងមូលដ្ឋាននីមួយៗ និងការធានាផ្គត់ផ្គង់ឱ្យបានទាន់ពេលវេលា និងមិនត្រូវខ្វះវ៉ាក់សាំងជូនដល់បណ្តារាជធានី-ខេត្ត។

ទី៣-គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស, អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ និងគណៈអភិបាលរាជធានី-ខេត្តទាំងអស់ ត្រូវសហការគ្នាបង្កើនការយកចិត្តទុកដាក់ក្នុងការអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយបន្ថែមទៀតអំពីភាពចាំបាច់នៃការចាក់វ៉ាក់សាំងកូវីដ-១៩ ទាំងដូសមូលដ្ឋាន និងដូសជំរុញ ដើម្បីឱ្យប្រជាជនមកទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យបានគ្រប់ៗគ្នា។

ទី៤-គណៈអភិបាលរាជធានី-ខេត្តទាំងអស់ ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការចាត់វិធានការចាំបាច់នានា ក្នុងភូមិសាស្ត្រស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ដើម្បីពង្រឹង និងជំរុញការអនុវត្តវិធានការ "**៣កុំ ៣ការពារ**"

និងវិធានការសុវត្ថិភាពផ្នែកសុខាភិបាលផ្សេងទៀត ជាពិសេស ការពាក់ម៉ាស, ការរក្សាគម្លាតសុវត្ថិភាព និងការធ្វើអនាម័យជាប់ជាប្រចាំ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស គណៈអភិបាលរាជធានី-ខេត្ត និងយន្តការដែលមានការពាក់ព័ន្ធផ្សេងទៀត ត្រូវផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ៩កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមករា ឆ្នាំ២០២២
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល៖**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់រដ្ឋបាលរាជធានី ខេត្ត.
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០១ សរណន

## សារាចរណែនាំ

## ស្តីពី

## ការកំណត់យកទិវាននយោបាយឈ្នះ ឈ្នះ ថ្ងៃទី២៩ ខែធ្នូ នៅក្នុងប្រតិទិនប្រចាំឆ្នាំ ដោយមិនឈប់សម្រាក

អស់រយៈពេល២៣ឆ្នាំកន្លងមក ព្រះរាជាណាចក្រកម្ពុជាបានកំណត់យកថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ ជាការបញ្ចប់សង្គ្រាមស៊ីវិលទាំងស្រុងដោយមិនមានការបង្ហូរឈាម និងទទួលបានសន្តិភាពពេញលេញ តាមរយៈនយោបាយឈ្នះ ឈ្នះ ជាគោលនយោបាយដ៏ធំមួយក្នុងការដឹកនាំប្រទេសកម្ពុជា បន្ទាប់ពីឆ្លងកាត់នូវដំណាក់កាលសង្គ្រាម ដំណាក់កាលនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត ដំណាក់កាលសង្គ្រាមផង ចរចាផង រហូតដល់ការលេចឡើងនៃវត្តមានរបស់នយោបាយឈ្នះ ឈ្នះ ។ ដើម្បីដឹងគុណ កត្តញ្ញូ និងចងចាំគុណូបការៈដ៏ថ្លៃថ្លានេះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ ៖

១.គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈ ឯកជន ត្រូវកំណត់យកទិវាននយោបាយឈ្នះ ឈ្នះថ្ងៃទី២៩ ខែធ្នូ ទៅក្នុងប្រតិទិនប្រចាំឆ្នាំ ដោយមិនឈប់សម្រាក ចាប់ពីឆ្នាំ២០២២តទៅ ។

២.គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈ ឯកជន ត្រូវរៀបចំចងបដា ពាក្យស្លោកដើម្បីអបអរសាទរទិវាននយោបាយឈ្នះ ឈ្នះ ដែលមានខ្លឹមសារថា "អរគុណសន្តិភាព! អរគុណនយោបាយឈ្នះ ឈ្នះ! ដឹងគុណស្ថាបនិក មគ្គុទ្ទេសក៏ឯក និងប្រតិបត្តិករនយោបាយឈ្នះ ឈ្នះ ដែលនាំមកនូវសន្តិភាព និងការឯកភាពជាតិពេញលេញ!" ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាល រាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់ ។

ថ្ងៃ សុក្រ ១២កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- -ក្រសួងព្រះបរមរាជវាំង
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- -គ្រប់ក្រសួង ស្ថាប័ន
- -រដ្ឋបាលរាជធានី ខេត្ត
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ..០០១......សហវ...ប្រក

## ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានគណៈកម្មការវិនិយោគសាធារណៈ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ស្ដីពីការគ្រប់គ្រងការវិនិយោគសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ស្ដីពីការដាក់ឱ្យប្រើប្រាស់ស្តង់ដារនីតិប្រតិបត្តិសម្រាប់ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ដែលទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញប្រកាសលេខ ៤៩៥ សហវ.ប្រក ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលការប្រព្រឹត្តទៅនៃនាយកដ្ឋាន និង អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៣០៨ សហវ.ប្រក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និង អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៣៧៣ សហវ.ប្រក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និង អង្គភាពក្រោមឱវាទរបស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៦៦៦ សហវ.ប្រក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និង អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១១៨ សហវ.ប្រក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមការិយាល័យមួយចំនួនក្រោមឱវាទអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាស ៧១១ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាស ១៤២៨ សហវ.ប្រក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ ស្ដីពីការបង្កើតអង្គភាពភាពជាដៃគូរវាងរដ្ឋនិងឯកជនថ្នាក់កណ្ដាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៣៤២ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និង អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៤៨៧ សហវ.ប្រក ចុះថ្ងៃទី ៣ ខែសីហា ឆ្នាំ២០២១ ស្ដីពីការបង្កើតគណៈកម្មការវិនិយោគសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ ._**

ប្រកាសនេះ មានគោលបំណងធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការបំពេញការងារ របស់លេខាធិការដ្ឋានគណៈកម្មការវិនិយោគសាធារណៈ **"គ.វ.ស."** ។

**ប្រការ ២ ._**

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.វ.ស.** ក្នុងនោះមានការកំណត់មុខងារនិងភារកិច្ច, ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង, ការប្រើប្រាស់ធនធាននិងសម្របសម្រួលកិច្ចដំណើរការ។

**ប្រការ ៣ ._**

លេខាធិការដ្ឋាន **គ.វ.ស.** មានមុខងារ និងភារកិច្ច ដូចតទៅ÷

- ផ្តល់ការគាំទ្រដល់កិច្ចដំណើរការ **គ.វ.ស.** ក្នុងការបំពេញមុខងារជាឡាវបាល នៃការគ្រប់គ្រងវិនិយោគសាធារណៈ
- ត្រួតពិនិត្យភាពត្រូវគ្នានៃគម្រោងវិនិយោគសាធារណៈ និងពិនិត្យគុណភាពនៃការវិនិយោគសាធារណៈ លើទិដ្ឋភាពសំខាន់ៗដូចជា ទិសដៅនិងអាទិភាពគោលនយោបាយ, ផលសេដ្ឋកិច្ចនិងសង្គម, និងចីរភាពហិរញ្ញវត្ថុសាធារណៈ ជាដើម ដើម្បីលើកយោបល់ជូន **គ.វ.ស.** ក្នុងការពិនិត្យជ្រើសរើសគម្រោង
- អនុវត្តតាមការណែនាំរបស់ **គ.វ.ស.** លើកិច្ចការគ្រប់គ្រង និងសម្របសម្រួលយន្តការគាំទ្រហិរញ្ញវត្ថុ ព្រមទាំងពិនិត្យលើសំណើគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោងវិនិយោគសាធារណៈ ដើម្បីលើកយោបល់ ជូន **គ.វ.ស.**
- ពិនិត្យ វិភាគ និងវាយតម្លៃ សំណើគម្រោងវិនិយោគសាធារណៈ ដែលមានទំហំធំ និងគម្រោងផ្សេងៗទៀត តាមការណែនាំពី **គ.វ.ស.** ដើម្បីលើកយោបល់ជូន **គ.វ.ស.**
- សម្របសម្រួល និងគ្រប់គ្រងការងារពាក់ព័ន្ធនឹងការជួលក្រុមហ៊ុនកុងស៊ុលតង់ ឬទីប្រឹក្សាបច្ចេកទេសសម្រាប់ពិនិត្យនិងវាយតម្លៃគម្រោងវិនិយោគ ដែលមានលក្ខណៈស្មុគស្មាញខ្លាំងផ្នែកបច្ចេកទេស ទៅតាមការសម្រេចរបស់ **គ.វ.ស.**
- សម្របសម្រួលការងារ ជូន **គ.វ.ស.** លើការកំណត់ប្រភពហិរញ្ញប្បទាន សម្រាប់គម្រោងវិនិយោគសាធារណៈដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់
- អនុវត្តតាមការណែនាំរបស់ **គ.វ.ស.** ក្នុងការរៀបចំរបាយការណ៍ និងបញ្ជីគម្រោងវិនិយោគសាធារណៈអាទិភាពដែលបានជ្រើសរើស និងមានប្រភពហិរញ្ញប្បទានជាក់លាក់ ដើម្បីគោរពជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និង សម្រេច
- ពិនិត្យសំណើកែសម្រួលគម្រោងវិនិយោគសាធារណៈ រួចផ្តល់យោបល់ជូន **គ.វ.ស.**
- តាមដាន និងវាយតម្លៃ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព នៃការវិនិយោគសាធារណៈ តាមការណែនាំរបស់ **គ.វ.ស.**
- រៀបចំរបាយការណ៍វឌ្ឍនភាព និងបញ្ជីគម្រោងប្រចាំឆ្នាំ ជូន **គ.វ.ស.**

- សហការ និងសម្របសម្រួល ជាមួយក្រសួង-ស្ថាប័ន រួមទាំងអគ្គនាយកដ្ឋាននិងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកិច្ចការពាក់ព័ន្ធនឹងគម្រោងវិនិយោគសាធារណៈ
- សម្របសម្រួល រៀបចំកិច្ចប្រជុំ និង បូកសរុបរបាយការណ៍ តាមការណែនាំរបស់ **គ.វ.ស.**
- បំពេញការងារផ្សេងទៀត តាមការណែនាំរបស់ប្រធាន **គ.វ.ស.**។

**ប្រការ ៤ ._**

អគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលបន្ទុកជាលេខាធិការដ្ឋាន **គ.វ.ស.** ដែលមានអគ្គនាយក ជាប្រធានលេខាធិការដ្ឋាន និងអគ្គនាយករងមួយរូប ជាអនុប្រធានលេខាធិការដ្ឋាន សម្រាប់ដឹកនាំប្រតិបត្តិការ និងការងារប្រចាំថ្ងៃ។

លេខាធិការដ្ឋាន **គ.វ.ស.** អាចជ្រើសរើសទីប្រឹក្សាបច្ចេកទេស និង មន្ត្រីជាប់កិច្ចសន្យា ដើម្បីបំពេញការងារទៅតាមតម្រូវការចាំបាច់។

**ប្រការ ៥._**

ចំណាយសម្រាប់ការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.វ.ស.** ត្រូវគ្រោងក្នុងគម្រោងថវិកាកម្មវិធីប្រចាំឆ្នាំ ដោយភ្ជាប់ជាមួយថវិកា នៃអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លេខាធិការដ្ឋាន **គ.វ.ស** អាចស្នើសុំការឯកភាពពីប្រធាន **គ.វ.ស.** និងការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការប្រើថវិកាគាំទ្រពីប្រភពហិរញ្ញប្បទានស្របច្បាប់ផ្សេងៗទៀត។

លេខាធិការដ្ឋាន **គ.វ.ស.** អាចទទួលបានការលើកទឹកចិត្តផ្សេងៗទៅតាមការឯកភាពពីប្រធាន **គ.វ.ស.** និងការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៦._**

អគ្គនាយកដ្ឋានគោលនយោបាយ ត្រូវគ្រប់គ្រង និងសម្របសម្រួលកិច្ចការផ្ទៃក្នុងដើម្បីធានានិរន្តរភាពកិច្ចដំណើរការលេខាធិការដ្ឋាន **គ.វ.ស.** និងការងារផ្សេងទៀតនៃអគ្គនាយកដ្ឋានគោលនយោបាយ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ប្រការ ៧ ._**

អគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកាតព្វកិច្ចសហការ ដើម្បីគាំទ្រដល់កិច្ចដំណើរការរបស់លេខាធិការដ្ឋាន **គ.វ.ស.**។ ក្នុងករណីចាំបាច់ **គ.វ.ស.** ត្រូវសម្របសម្រួល ដើម្បីធានាប្រសិទ្ធភាពការងារ ប្រកបដោយសុខដុមភាព ស្របតាមទិសដៅនិងជំហានកំណែទម្រង់។

**ប្រការ ៨ ._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩.-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីទទួលបន្ទុកអគ្គនាយកដ្ឋាន នាយកខុទ្ទកាល័យ រដ្ឋលេខាធិការទទួលបន្ទុកអគ្គ-នាយកដ្ឋាន អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និង ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៦ កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែ មករា ឆ្នាំ២០២២

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ០១១..................

ថ្ងៃ.................. ខែ.................. ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០.... ខែ........ ឆ្នាំ២០២២

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ០៦០/១៤ គ.ត.ស.ព ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតគ្រឿងបន្លាស់កង់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់ក្រុមហ៊ុន ដា ចាវ សុង ខូ អិលធីឌី

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ដា ចាវ សុង ខូ អិលធីឌី **(DA CHAO SHONG CO., LTD.)** តំណាងដោយលោក **CHEN, WEI-CHIN** សញ្ជាតិចិន (តៃវ៉ាន់) កាន់លិខិតឆ្លងដែនលេខ316122201 ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ បង្កើតរោងចក្រផលិតគ្រឿងបន្លាស់កង់ ដែលមានទីតាំងស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេសតាយសេងបាវិត (សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង)។

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| គ្រឿងបន្លាស់កង់ | ៣០៩២ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " រោងចក្រផលិតគ្រឿងបន្លាស់កង់ ជា ចាវ សុង ខូ អិលធីឌី "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ៤៣០ ឧស.កឧ.ប្រក.១២ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**មាន សុភា**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តស្វាយរៀង
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តស្វាយរៀង
-អង្គភាពរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសតាយសេងបាវិត
-រដ្ឋបាលក្រុងបាវិត
-រដ្ឋបាលសង្កាត់បាវិត
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ០០៤៥ ឧ.វ.ប.ន. ឧ.ក.រ

ថ្ងៃ........................ ខែ.............. ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី....១០.... ខែ............ ឆ្នាំ២០២២

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ១០៦៣/១៩ គ.វ.ក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្តូរវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រុមហ៊ុន វីកម៉ាក ហ្វេសិន (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន វីកម៉ាក ហ្វេសិន (ខេមបូឌា) ឯ.ក (VICMARK FASHIONS (CAMBODIA) CO., LTD.) តំណាងដោយលោកស្រី GUI, SHANSHAN សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ EE4086947 ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅដីឡូត៍លេខ២០៧១ ភូមិព្រៃព្រីងខាងជើង១ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " រោងចក្រកាត់ដេរសម្លៀកបំពាក់ វីកម៉ាក ហ្សេិន (ខេមបូឌា) ឯ.ក "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្ដល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្ដន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ១៥៤ ឧស.កឧ.ប្រក.០៥ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងលិខិតលេខ៥១៨២ ឧវបន.កឧ.លស ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ដីពីការប្ដូរប្រធានក្រុមប្រឹក្សាភិបាល និងប្ដូរទីតាំងរោងចក្រ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**ហាន សុភា**

**ចម្លងជូន៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រាជកិច្ច
- វិទ្យាស្ថានស្តង់ដារកម្ពុជា
- មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សាលារាជធានីភ្នំពេញ
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ
- រដ្ឋបាលសង្កាត់ចោមចៅទី៣

  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ០០.៣.....ឧ.វ.ក.....

ថ្ងៃ.................. ខែ.............. ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី......... ខែ......... ឆ្នាំ២០២...

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ៣៦៤០/១៨ គ.វ.ក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្តូរវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រុមហ៊ុន ឌីន លីង ហ្គាម៉ិន ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ឌីន លីង ហ្គាម៉ិន ឯ.ក (**DIN LING GARMENT CO., LTD.**) តំណាងដោយលោក **WANG, CHIH-WEI** សញ្ជាតិចិន(តៃវ៉ាន់) កាន់លិខិតឆ្លងដែនលេខ **312064887** ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៥ បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅផ្លូវវែងស្រេង សួនឧស្សាហកម្មកាណាឌីយ៉ា អគារលេខ១៤, ១៥, ១៦ និង១៧ ភូមិត្រពាំងថ្លឹង២ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ "រោងចក្រកាត់ដេរសម្លៀកបំពាក់ ឌីន លីង ហ្គាម៉ិន ឯ.ក "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

